## ការជួសជុលសំណង (reparation)

ការជួសជុលសំណង ជាសកម្មភាព បំណងជួសជុល ការខូចខាតបង្កដោយបទល្មើស។ នេះអាចរាប់បញ្ចូល ការធ្វើឲ្យមានស្ថានភាពដូចដើមវិញ (restitution) ដល់ជនរងគ្រោះ (victim)។

វាមានវិសាលភាពទូលាយ ទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះ និងជួសជុលសំណង។ និន្នាការនេះខុសពីសម័យដើម ដែលប្រព័ន្ធយុត្តិធម៌ ផ្តោតខ្លាំងលើការដាក់ទោសលើជនល្មើស (retribution)។ ការជួសជុល ជាការបំពេញបន្ថែមលើទោសទណ្ឌដល់ជនល្មើស ឬករណីខ្លះ ជាវិធានការជំនួសការដាក់ទោសទណ្ឌលើជនល្មើស។ ការជួសជុលសំណង ធ្វើឡើងតាមរយៈដីការបស់តុលាការ (compensation order)។

វាទាមទារផងដែរ ឲ្យជនល្មើសទទួលខស្គាល់នូវអំពើខុសឆ្គងដែលខ្លួន បានប្រព្រឹត្តលើជនរងគ្រោះ (Eugene McLaughlin and John Muncie, the Sage Dictionary of Criminology, 2nd Ed., Extraterritorial Law Enforcement, 2003, pp. 159-160)។

**ខ្លឹមសារបន្ថែម៖** អត្ថបទខ្លះ បង្ហាញថា ពាក្យ “reparation” ជាពាក្យរួម ដែលគ្រោប សំណង (compensation) ការធ្វើឲ្យដូចស្ថានភាពដើម (restitution) ការបំពេញចិត្ត (satisfaction) ដែលរាប់បញ្ចូលការសុំទោស ឬការឲ្យធានាអះអាងថា ថាអំពើល្មើសដដែល នឹងមិនកើតមាននាពេលអនាគត (non-repetition)។